ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៤២

ចុះថ្ងៃទី២១ខែមិថុនាឆ្នាំ២០០០

សាលដីកា

លេខ : ១៥៥

ចុះថ្ងៃទី ០៨ខែសីហាឆ្នាំ២០០០

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណះ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ប៉ែន ស៊ិន ជាចៅក្រមរបាយការណ៍

៣- លោក ស៊ិន នឹម ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី យុត សុគន្ធា

តំណាងមហាអយ្យការ

ឯកឧត្តម ដួន ស៊ិនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើសំណុំរឿងរដ្ឋប្បវេណីលេខ ២៤២ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ របស់ តុលាការកំពូល ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំកែតម្រូវលេខផ្ទះទំនាស់ពីលេខ ២០៧ ផ្លូវ ១៨០ ក្រុម ២៦ មកជាផ្ទះលេខ ២៦០ ផ្លូវ ១៥០ ក្រុម ២៦ សង្កាត់ទឹកល្អក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៣-០៦-២០០០ របស់ឈ្មោះ ទ្រិញ ណារិន បានសុំអោយតុលាការកំពូលធ្វើការកែតម្រូវលេខផ្ទះរបស់ឈ្មោះ ទៀម សាហួត ដោយហេតុថា : ក្នុងការសំរេចសេចក្តីរបស់ សាលាក្រម ក៏ដូចសាលដីកា ឃើញថាមានការភ័ន្តច្រឡំលើលេខផ្ទះ ដែលបានសង់រំលោភបំពាន គឺ ផ្ទះលេខ ២៦០ ក្រុម ២៦ ផ្លូវ ១៥០ សង្កាត់ទឹកល្អក់ ២ ខ័ណ្ឌទួលគោក មិនមែនផ្ទះលេខ ២០៧ ផ្លូវ ១៨០ ទេ ។ ដោយការភ័ន្តច្រឡំលើលេខផ្ទះរបស់ចុងចម្លើយនេះ ធ្វើអោយតុលាការក្រុង ពុំអាចអនុវត្ត សាលដីការបស់តុលាការកំពូលបាន ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ទ្រិញ ណារិន ដែលបានឆ្លើយនៅពេលសវនាការ -

ថា :- ខ្លួនប្តឹងពីផ្ទះលេខ ២៦០ ផ្លូវ ១៥០ មិនមែនប្តឹងពីផ្ទះលេខ ២០៧ ផ្លូវ ១៨០ ទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី ទ្រិញ ណារិន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៣-៦-២០០០ របស់ អ្នកស្រី ទ្រិញ ណារិន សុំអោយតុលាការកំពូល ធ្វើការកែតម្រូវលេខផ្ទះរបស់លោក ទៀម សាហួត មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

- យល់ឃើញថា ផ្ទះលោក ទៀម សាហួត ដែលបានសង់ឡើងពីនគររូបនីយបញ្ញត្តិនោះមានលេខ ២៦០ ផ្លូវ ១៥០ ក្រុមទី២៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ពុំមែនលេខ ២០៧ ផ្លូវ ១៨០ ដូចមានចែងក្នុងចំណុចទី៤ នៃ សាលក្រមរដ្ឋប្បវេណីលេខ ២០ "ក" ចុះថ្ងៃទី ០៣-៣-៩៩ របស់ តុលាការក្រុងភ្នំពេញនោះទេ ។ ប៉ុន្តែដោយកំហុសនេះជាកំហុសសម្ភារៈ តុលាការកំពូលសម្រេចកែតម្រូវបាន ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រី ទ្រិញ ណារិន

១-ទទួលពាក្យសុំកែតម្រូវលេខផ្ទះ របស់អ្នកស្រី ទ្រិញ ណារិន ចុះថ្ងៃទី ១៣-៦-២០០០ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-កែតម្រូវសាលដីការដ្ឋប្បវេណីលេខ ៨៧ ចុះថ្ងៃទី០៤-៥-២០០០ របស់ តុលាការកំពូល ត្រង់ចំណុចទី២ ទៅជា "តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី ០៦-៩-៩៩ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ ដោយកែតម្រូវលេខផ្ទះត្រង់ចំណុចទី៤ នៃ សាលក្រមរដ្ឋប្បវេណីលេខ ២០ "ក" ចុះថ្ងៃទី ០៣-៣-៩៩ របស់តុលាការក្រុងភ្នំពេញ ពីផ្ទះលេខ ២០៧ ផ្លូវ ១៨០ ទៅជាផ្ទះលេខ ២៦០ ផ្លូវ ១៥០ ក្រុម ២៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោកវិញ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលអ្នកស្រី ទ្រិញ ណារិន បានបង់រួចហើយ គឺ :-

-ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛០០

សរុប ១៩.០០០៛០០ ។

៤- សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី ០៨ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១១-៨-២០០០ ។